# ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាស

*រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ១៩៩៤*

**ប្រកាសលេខ ៖ ២៨២ ពណ.ចក.ប្រក**
**ស្តីពីសិទ្ធិចុះហត្ថលេខាលើលិខិតបទដ្ឋាន**
**ស្តីពីប្រព័ន្ធអនុគ្រោះទូទៅ ( GSP )**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ចុះថ្ងៃទី ២៤-១០-១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤

## សំរេច

**ប្រការ ១ ៖** ប្រកាសលេខ ២១៧ ពណ.ប្រក ចុះថ្ងៃទី ០២-៩-១៩៩៤ របស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២ ៖** សិទ្ធិចុះហត្ថលេខាលើលិខិតបទដ្ឋាន ដែលមានទំនាក់ទំនងអន្តរជាតិប្រព័ន្ធអនុគ្រោះទូទៅ ( G S P ) ជាសិទ្ធិរបស់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ ក្នុងករណីរដ្ឋមន្ត្រីអវត្តមាន ដោយជាប់បំពេញបេសកកម្មនៅក្រៅប្រទេស រដ្ឋលេខាធិការ មានសិទ្ធិចុះហត្ថលេខាជាស្វ័យប្រវត្តិ ។

**ប្រការ ៣ ៖** ប្រធានមន្ទីរក្រសួង ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ចម ប្រសិទ្ធ**